# កម្មវិធីគោលនយោបាយអាទិភាព
# សម្រាប់វិស័យកសិកម្ម

# កម្មវិធីគោលនយោបាយជាតិ

កម្មវិធីគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល
ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចិរភាព

១. ការផ្តល់ការថែទាំសុខភាពជាសកល
២. ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេស
៣. ស្ថាបនូបនីយកម្មកម្មវិធីជាតិជំនួយសង្គម
៤. ការជំរុញការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ
៥. ការជំរុញទីផ្សារ ផលិតកម្ម និងការរក្សាលំនឹងថ្លៃកសិផល
៦. ការដាក់ពង្រាយមន្ត្រីកសិកម្ម និងការរៀបចំឱ្យមានសមាគមកសិករ






# កម្មវិធីគោលនយោបាយអាទិភាព សម្រាប់វិស័យកសិកម្ម

- (៥) ការជំរុញទីផ្សារ ផលិតកម្ម និងការរក្សាលំនឹងថ្លៃកសិផល
- (៦) ការដាក់ពង្រាយមន្ត្រីកសិកម្មឃុំ និង ការរៀបចំឱ្យមានសមាគមកសិករ

ប្រកាសឱ្យប្រើប្រាស់នៅថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ២០២៣ ក្រោមអធិបតីភាពរបស់សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត



# កម្មវិធីគោលនយោបាយ ការជំរុញទីផ្សារ ផលិតកម្ម និង ការរក្សាលំនឹងថ្លៃ កសិផល



# ការជំរុញទីផ្សារ ផលិតកម្ម និងការរក្សាលំនឹងថ្លៃកសិផល

- ជាយន្តការសម្របសម្រួលនិងកម្មវិធីហិរញ្ញប្បទាន សំដៅ
  - លើកស្ទួយផលិតកម្ម
  - រកទីផ្សារ
  - រក្សាលំនឹងថ្លៃកសិផលសំខាន់ៗក្នុងកម្រិតសមរម្យ
- កញ្ចប់ថវិកាជាក់លាក់ ដោយចាប់ផ្តើមពីចំនួន ១០០ លានដុល្លារអាមេរិក និងអាចវិភាជថវិកាបន្ថែម

# ផលប្រយោជន៍

- បង្កើនប្រាក់ចំណូលដល់ប្រជាកសិករ
- លើកទឹកចិត្តដល់កសិករក្នុងការងារផលិតកម្មកសិកម្ម
- រក្សាសន្តិសុខស្បៀងសម្រាប់សហគមន៍ និងនៅក្នុងប្រទេស
- រក្សាលំនឹងនិរន្តរភាពផលិកម្មកសិកម្ម
- បង្កើនបរិមាណ និងគុណភាពនៃផលិតកម្មកសិកម្មសម្រាប់ផ្គត់ផ្គង់ការនាំចេញ។



# ដំណើរការគ្រប់គ្រង

- ផ្តោតលើកិច្ចអន្តរាគមន៍ឱ្យបានទាន់ពេលវេលា ដើម្បីរក្សាស្ថិរភាពថ្លៃនៅពេលប្រមូលផល
- អនុវត្តដោយក្រុមការងារចម្រុះសម្របសម្រួលអន្តរស្ថាប័ន
- វិធានការសំខាន់ៗ
  - វិធានការទូទៅដែលមានឥទ្ធិពលលើថ្លៃកសិផល
  - វិធានការគ្រប់គ្រងថ្លៃកសិផលផ្ទាល់

# វិធានការទូទៅ

- ផ្អែកលើគោលការណ៍សេដ្ឋកិច្ចទីផ្សារសេរី
- អាស្រ័យទៅលើបរិមាណនៃការផ្គត់ផ្គង់ និងតម្រូវការជាក់ស្ដែង៖ ផលិតកម្ម ការកែច្នៃ និងការនាំចូល តម្រូវការទីផ្សារក្នុងស្រុក និងការនាំចេញ
- កិច្ចសម្រួលពាណិជ្ជកម្មមួយចំនួន រួមផ្សំនឹងការលុបបំបាត់បរិកប្បកម្ម ( Speculation )
- ការរៀបចំជាប្រព័ន្ធស្តុកបណ្ដោះអាសន្ន សម្រាប់ធ្វើអន្តរាគមន៍លើថ្លៃកសិផលផ្ទាល់ក្នុងករណីចាំបាច់
- ការកសាង និងផ្សារភ្ជាប់ជាមួយហេដ្ឋារចនាសម្ព័ន្ធគាំទ្រដូចជា កន្លែងសម្ងួត កន្លែងប្រមូលផ្តុំ និងឃ្លាំងស្តុក...
- ការអនុវត្តកិច្ចសន្យាផលិតកម្មកសិកម្ម ការអភិវឌ្ឍសហគមន៍កសិកម្មទំនើប ការកំណត់តំបន់គោលដៅសក្តានុពលផលិតផលកសិកម្ម ការគ្រប់គ្រងបច្ចេកវិទ្យាក្រោយប្រមូលផល ការសម្រួលចលនាកសិផលពីតំបន់មួយទៅតំបន់មួយដែលខ្វះខាត និងការរៀបឱ្យមានការធានារ៉ាប់រងកសិកម្ម ។ល។

# វិធានការគ្រប់គ្រងថ្លៃកសិផលផ្ទាល់

- មានលក្ខណៈបន្ទាន់ និងបណ្ដោះអាសន្ន (សម្រាប់ប្រើតែក្នុងករណីចាំបាច់បំផុតតែប៉ុណ្ណោះ)
- ការកំណត់ថ្លៃពិតានខ្ពស់បំផុត (Ceiling Price)
- ការកំណត់តម្លៃទាបបំផុត (Minimum Floor Price) ដែលអនុញ្ញាតឱ្យធ្វើពាណិជ្ជកម្មស្របច្បាប់
- ការបញ្ចេញស្តុកយុទ្ធសាស្ត្រ
- ការបញ្ចេញថវិកាប្រមូលទិញដើម្បីទប់ទល់នឹងការធ្លាក់ថ្លៃ
- ផ្អែកលើទស្សនវិស័យរយៈពេលវែង ដោយត្រូវធានាឱ្យបាន៖
  - ជួយសម្រាលស្ថានភាព
  - ជំរុញមានភាពប្រក្រតីនៃតុល្យភាពនៃការផ្គត់ផ្គង់និងតម្រូវការ ឱ្យបានឆាប់រហ័ស



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១១២៩៩១

សេចក្តីសម្រេច
ស្តីពី
ការបង្កើតក្រុមការងារចម្រុះសម្របសម្រួលខ្សែច្រវាក់តម្លៃផលិតផលកសិកម្ម

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧២៣/១៥៦៣ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

១/៣

# ក្រុមការងារចម្រុះ

សម្របសម្រួលដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

មានសមាសភាពមកពី៖

ក្រសួងពាណិជ្ជកម្ម

ធនាគារអភិវឌ្ឍជនបទនិងកសិកម្ម

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អភិបាលនៃគណៈអភិបាលខេត្ត

វិស័យឯកជន

សហគមន៍កសិកម្ម



# ការដាក់ពង្រាយមន្ត្រីកសិកម្មឃុំ-សង្កាត់



# ការដាក់ពង្រាយមន្ត្រីកសិកម្មឃុំ-សង្កាត់

## ដើម្បី

- បង្កើនប្រសិទ្ធភាពសេដ្ឋកិច្ចកសិកម្ម សម្រាប់គ្រួសារកសិករ តាមរយៈ
  - ការជំរុញការអនុវត្តបច្ចេកទេសកសិកម្មមាននិរន្តរភាព ធន់នឹងការប្រែប្រួលអាកាសធាតុ
  - ការសាងប្រព័ន្ធផលិតកម្មផ្សារភ្ជាប់នឹងទីផ្សារ

## ការរំពឹងទុក

- ថ្នាក់ជាតិនិងមូលដ្ឋាន សហការគ្នាកាន់តែរលូន និងជិតស្និទ្ធ
- កសិករទទួលបានភាពកក់ក្ដៅ និងជំនឿចិត្តកាន់តែខ្ពស់

# ផលប្រយោជន៍សម្រាប់កសិករ និងរដ្ឋាភិបាល

| កសិករទទួលបាន | រដ្ឋាភិបាលទទួលបាន |
| --- | --- |
| • បច្ចេកទេសកសិកម្មសមស្រប<br>• ព័ត៌មានទីផ្សារ និងពីគ្រោះមហន្តរាយ សម្រាប់តម្រង់ទិសផលិតកម្ម<br>• ការពិគ្រោះយោបល់សម្រាប់កាត់បន្ថយថ្លៃដើមផលិតកម្ម<br>• ការសម្របសម្រួលការអនុវត្តកិច្ចសន្យាកសិកម្ម និងការអភិវឌ្ឍសហគមន៍កសិកម្មទំនើប | • ស្ថិតិ និងព័ត៌មានកសិកម្មកាន់តែសុក្រឹត<br>• ព័ត៌មានស្តីពីបញ្ហាប្រឈមរបស់កសិករទាន់ពេលវេលា<br>• ការផ្តល់ព័ត៌មានពីគោលនយោបាយ និងផែនការកសិកម្មកាន់តែងាយស្រួល<br>• ការអភិវឌ្ឍសហគមន៍កសិកម្មទំនើប |

# តួនាទីនិងភារកិច្ចរបស់មន្ត្រីកសិកម្មឃុំ-សង្កាត់

- តួនាទី៖ ជាអ្នកសម្របសម្រួលរវាងកសិករ និងភាគីពាក់ព័ន្ធ ដើម្បីទទួលបានសេវាគាំទ្រ និងដោះស្រាយបញ្ហាប្រឈម
- ភារកិច្ច
  - កំណត់បញ្ហាប្រឈមជាក់ស្តែងរបស់កសិករ តាមស្ថានភាពតំបន់
  - រាយការណ៍បញ្ហាប្រឈមមកអង្គភាពជំនាញតាមឋានានុក្រម
  - គាំទ្រដល់ការអនុវត្តដំណោះស្រាយដែលបានផ្តល់ជូនកសិករ
  - សម្របសម្រួល និងពង្រឹងសហគមន៍កសិកម្មក្នុងខ្សែប្រវាក់ផលិតកម្មឆ្ពោះទៅទីផ្សារ
  - ប្រមូលស្ថិតិកសិកម្ម

# ការជ្រើសរើស និងដាក់ពង្រាយ



សរុបចំនួន ១៦០០ នាក់

- ២០២៣ - ២៥០ នាក់ (សាកល្បងនៅជើងព្រៃ ១០ឃុំ)
- ២០២៤ - ៨០០ នាក់
- ២០២៥ - ៥៥០ នាក់

- ពង្រាយសម្រាប់ឃុំមានសកម្មភាពកសិកម្ម
- មន្ត្រីម្នាក់កាន់ ១ឃុំ
- ជាមន្ត្រីក្របខ័ណ្ឌ

# លក្ខខណ្ឌជ្រើសរើស

- រៀនថ្នាក់បរិញ្ញាបត្ររងឡើងទៅ លើជំនាញកសិកម្ម និងជំនាញពាក់ព័ន្ធ
- មានបទពិសោធន៍ការងារកសិកម្ម និងធ្វើការជាមួយកសិករ
- មានលំនៅដ្ឋាននៅឃុំ ឬស្រុកគោលដៅ
- ចូលចិត្តធ្វើការជាមួយកសិករ និងចេះធ្វើការជាក្រុម
- មានសក្តានុពលក្នុងការអភិវឌ្ឍខ្លួនឯង
- ជាកម្មសិក្សាការីយ៉ាងតិចចំនួន១ ឆ្នាំ





# ការអភិវឌ្ឍ សហគមន៍ កសិកម្ម ទំនើប

# ការអភិវឌ្ឍសហគមន៍កសិកម្មទំនើប

## អ្វីជាសហគមន៍កសិកម្ម?

- សហគមន៍កសិកម្មគឺជាសហគ្រាសសេដ្ឋកិច្ចកសិកម្ម ដែលមានប្រជាកសិករខ្លួនឯងផ្ទាល់រួមគ្នាធ្វើជាម្ចាស់កម្មសិទ្ធិ
  - មានមុខរបរចម្បងពាក់ព័ន្ធនឹងវិស័យកសិកម្ម
  - ស្ម័គ្រចិត្ត រួមគ្នាបង្កើតដើមទុន និងគ្រប់គ្រងតាមលក្ខណៈប្រជាធិបតេយ្យ
  - ពង្រឹងសមត្ថភាពផ្នែកផលិតកម្មកសិកម្ម កសិ-ពាណិជ្ជកម្ម កសិ-ឧស្សាហកម្ម និងសេវាកម្ម
  - លើកកម្ពស់ជីវភាពរបស់សមាជិក និងចូលរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិ

# ការអភិវឌ្ឍសហគមន៍កសិកម្មទំនើប

## ដើម្បីអ្វី?

- កសិកម្មកម្ពុជាពីលក្ខណៈគ្រួសារឱ្យទៅជាសហគ្រាសសេដ្ឋកិច្ចកសិកម្មដ៏រឹងមាំ
- មានសមាហរណកម្មខ្ពស់
- មានសេដ្ឋកិច្ចមាត្រដ្ឋាន (Economies of Scale)
- មានសមត្ថភាពប្រកួតប្រជែងទាំងបរិមាណ និងគុណភាព

# ផលប្រយោជន៍នៃសហគមន៍កសិកម្មទំនើប

- ការលើកកម្ពស់អំណាចចរចាទីផ្សារ ទិញ/លក់
- ការកាត់បន្ថយថ្លៃដើមផលិតកម្ម
- បង្កើនប្រាក់ចំណេញឱ្យបានជាអតិបរមាពីសេដ្ឋកិច្ចមាត្រដ្ឋាន
- ការគាំទ្របច្ចេកទេស សម្ភារៈ ហេដ្ឋារចនាសម្ព័ន្ធ  បច្ចេកវិទ្យា និងការប្រឹក្សាយោបល់លើផលិតកម្ម និងមុខជំនួញ
- ទីផ្សារកសិផលទូលំទូលាយ និងមានសមត្ថភាពអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា
- ការគាំទ្រលើទុនបង្វិល និងប្រាក់កម្ចីសម្រាប់ប្រតិបត្តិការ និងការពង្រីកអាជីវកម្ម
- ការកាត់បន្ថយហានិភ័យពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ
- ភាពប្រសើរឡើងជីវភាពរបស់កសិករជាសមាជិក

# លក្ខណៈរបស់សហគមន៍ទំនើប

- កសិករផលិតកម្មកសិកម្មរួមគ្នា និងមានការគ្រប់គ្រងរួមប្រកបដោយវិជ្ជាជីវៈខ្ពស់
- ទិញរួម ផលិតរួម លក់រួម និងគ្រប់គ្រងរួមដោយសហគមន៍
- បែងចែកប្រាក់ចំណេញទៅតាមសមាមាត្រនៃភាគហ៊ុន
- ជម្រើសទី១៖ ជួលដីផលិតកម្ម ឬម៉ៅដំណាំ ពីសមាជិក ដើម្បីយកទៅផលិតរួមគ្នា
- ជម្រើសទី២៖ ដាក់ដីផលិតកម្ម ឬដំណាំ ជាភាគហ៊ុន ដើម្បីយកទៅផលិតរួមគ្នា

# រចនាសម្ព័ន្ធដឹកនាំ



# នីតិវិធីបង្កើតសហគមន៍កសិកម្មទំនើប

១
- ផ្សព្វផ្សាយគោលគំនិតស្តីពីសហគមន៍កសិកម្មទំនើប និងអង្កេតទស្សនៈរបស់កសិករ

២
- បង្កើតគណៈកម្មការសម្រាប់បង្កើតសហគមន៍ កសិកម្មទំនើប

៣
- រៀបចំមហាសន្និបាតកំណើតដំបូង

៤
- រៀបចំឯកសារចាំបាច់សម្រាប់ចុះបញ្ជីផ្លូវការ

៥
- រៀបចំគណៈគ្រប់គ្រងរបស់សហគមន៍កសិកម្មទំនើប



# កត្តាជោគជ័យ

- ធនធានមនុស្សប្រកបដោយគុណវុឌ្ឍិ និងកម្រិតវិជ្ជាជីវៈខ្ពស់
- ប្រព័ន្ធគ្រប់គ្រងច្បាស់លាស់ និងផែនការអាជីវកម្មរឹងមាំ
- ទំនុកចិត្ត និងភាពជឿជាក់ខ្ពស់ពីសំណាក់សមាជិកសហគមន៍ និងដៃគូពាក់ព័ន្ធ
- ភាពជាម្ចាស់ ប្រកបដោយសហគ្រិនភាព   ភាពស្មោះត្រង់ នវានុវត្តន៍ និងការប្រកួតប្រជែង
- វិសាលភាពធំ និងមានសេដ្ឋកិច្ចមាត្រដ្ឋាន
- និរន្តរភាពខាងផ្នែកសេដ្ឋកិច្ច និងមូលធនរឹងមាំ
- ភាពទាក់ទាញ និងការចូលរួមគាំទ្រ

# ភាពប្រទាក់ក្រឡាគ្នានៃគោលនយោបាយ

- មិនមែនជាកម្មវិធីគោលនយោបាយដាច់ដោយឡែក
- កម្មវិធីទាំងនេះ បំពេញឱ្យគ្នាទៅវិញទៅមក
- មិនជំនួសអន្តរាគមន៍ និងសកម្មភាពរបស់ក្រសួងកសិកម្ម នៅមូលដ្ឋាន

# សូមអរគុណ